ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ឯកសារស្រាវជ្រាវបទចម្រៀង និងបទសូត្រ

សម្រាប់កុមារ និងសិស្សានុសិស្ស

១. បទនគរាជ

២. បទដាក់ទង់ព្រះពុទ្ធសាសនា

៣. បទលើកទង់ព្រះពុទ្ធសាសនា

៤. បទគន់មើលទៅមេឃ

៥. បទដែនដីខ្មែរ

៦. បទពង្សាវតារខ្មែរ

៧. បទឆ្លុតបីប្រការ

រៀបចំសម្រាប់ប្រើប្រាស់ក្នុងការសិក្សា និងបង្រៀន

មាតិកា

១. បទនគររាជ	3
២. បទដាក់ទង់ព្រះពុទ្ធសាសនា	4
៣. បទលើកទង់ព្រះពុទ្ធសាសនា	5
៤. បទគន់មើលទៅមេឃ	6
៥. បទដែនដីខ្មែរ	7
៦. បទពង្សាវតារខ្មែរ	8
៧. បទឆ្លុតបីប្រការ	9

បទនគរវាត

សូមពួកទេវតា រក្សាមហាក្សត្រយើង
ឲ្យបានរុងរឿង ដោយជ័យមង្គលសិរីសួស្តី
យើងខ្ញុំព្រះអង្គ សូមជ្រកក្រោមម្លប់ព្រះបារមី
នៃព្រះនរបតី រង្សីក្សត្រាដែលសាងប្រាសាទថ្ម
គ្រប់គ្រងដែនខ្មែរ បុរាណថ្កើងថ្កាន។

ប្រាសាទសិលា កំបាំងកណ្តាលព្រៃ
គួរឲ្យស្រមៃ នឹកដល់យសស័ក្តិមហានគរ
ជាតិខ្មែរដូចថ្ម គង់រង្សីនៅល្អឹងប៉ឹងជំហរ
យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា
មហារដ្ឋកើតមាន យូរអង្វែងហើយ។

គ្រប់វត្តអារាម ឮតែសូរសព្ទធម៌
សូត្រដោយអំណរ រុំព្រះគុណពុទ្ធសាសនា
ចូរយើងជាអ្នក ជឿជាក់ស្មោះស្ម័គ្រតាមបែបដូនតា
គង់តែទេវតា នឹងជួយជ្រោមជ្រែងផ្តត់ផ្តង់ប្រយោជន៍ឲ្យ
ដល់ប្រទេសខ្មែរ ជាមហានគរ។

បទជាអំធេចព្រះពុទ្ធសាសនា

ជាតិយើងអ្នកកាន់សាសនា ត្រូវដឹងច្បាស់ថាព្រះពុទ្ធជិនស្រី
ទ្រង់មានឆព្វណ្ណរង្សី គឺព្រះរស្មីទាំងប្រាំមួយពណ៌ ។
ផ្សាយចេញពីព្រះកាយទ្រង់ រុងរឿងឫទ្ធិរង្គប្រសើរបវរ
ឆ្វៀលឆ្លាត់កាយឆើតឆាយល្អ ទាំងប្រាំមួយពណ៌ស្រស់ល្អសោភា ។
កំណើតនៃព្រះរស្មី កើតដោយបារមីនៃព្រះភគវា
ធ្វើទានឥតមានរួញរា កាលដែលនៅជាព្រះពោធិសត្វ ។
រស្មីពណ៌ខៀវនោះណា កាលឆ្មៀលនេត្រាទ្រង់ដោយចិត្តកាត់
ធ្វើទានដល់ឥន្ទព្រាហ្មណ៍ពិត កាលនៅជាក្សត្រនាមស្រីកិរាស្ត្រ។
រស្មីពណ៌លឿងភ្លឺថ្លា កាលដែលទ្រង់អារសោច់ផែធ្វើមាស
បិទពុទ្ធរូបភ្លឺល្អឱភាស ព្រះឥន្ទ្រជាងមាសទ្រង់វៃបណ្ឌិត ។
រស្មីក្រហមនោះណា កាលដែលមាតាពស់ខាំស្លាប់ពិត
បទុមស៊ូប្តូរជីវិត កាត់បេះដូងបិទធ្វើថ្នាំមាតា ។
រស្មីពណ៌សសុទ្ធសាធ កាលដែលព្រះបាទវេស្សន្តរក្សត្រា
ឱ្យទានដំរីសសោភា ដល់ព្រាហ្មណ៍ប្រាថ្នាយកពោធិញ្ញាណ។
រស្មីពណ៌ដូចជើងហង្ស កាលមាតាទ្រង់យក្ខចាប់យកបាន
វិជ្ជាធរអារសោច់ខ្លួនប្រាណ ឱ្យយក្ខសាមាន្យស៊ីប្តូរជីវិត ។
រស្មីពណ៌ផ្លេកពណ្ណរាយ កាលជាទន្សាយឈ្មោះសោមបណ្ឌិត
ឱ្យទានសាច់ឈាមជីវិត ដល់ឥន្ទព្រាហ្មណ៍គិតថាអត់អាហារ ។
រស្មីខៀវលឿងក្រហម សហង្សបាទព្រមភ្លឺផ្លេកអស្ចារ្យ
ត្រូវជាប្រាំមួយប្រការ ទាំងចាស់កុមារចូរចាំទុកអើយ ។

បទលើកទង់ព្រះពុទ្ធសាសនា

សូមមើលទង់ជ័យ ឆព្វណ្ណរង្សី ដែលមានរស្មីភ្លឺស្រស់ល្អ
ខៀវលឿងក្រហម ព្រមទាំងពណ៌ស ហង្សបាទនិងពណ៌ដ៏ភ្លឺផ្លេក ។
ប្រទេសគូចធំ បានស្ម័គ្រស្មោគម ជំនុំគ្នាច្រើនអនេក
ព្រមយករស្មី ព្រះពុទ្ធគួរគ្រេក ប្រសើរពន់ពេកក្រៃកន្លង ។
ធ្វើជាសញ្ញា ទង់ជ័យសាសនា នៃព្រះសម្ពុទ្ធចម្បង
ចូរយើងរាល់គ្នា យកចិត្តចាំចង នឹកដល់ព្រះអង្គជាអម្ចាស់ ។
ទោះជាតិផ្សេងគ្នា ក៏ត្រូវដឹងថា សុទ្ធសឹងតែជាពុទ្ធសាសន៍
ត្រូវមានសាមគ្គី ទាំងក្មេងទាំងចាស់ ប្រឹងប្រែងឱ្យណាស់គ្រប់ៗគ្នា ។
សូមសាសនា(ព្រះ)ពុទ្ធ ប្តុំថ្កើងខ្ពស់ផុត រុងរឿងវិសុទ្ធថ្លៃថ្លា
ហើយមានជ័យជោគ ផ្សាយពេញលោកា ដោយជនជ្រះថ្លារាប់ច្រើនលាន។
មានចិត្តស្នេហា គោរពបូជា ចំពោះព្រះធម៌ដ៏កល្យាណ
ទាំងមនុស្សទេវតា ស្នេហាគ្រប់ប្រាណ ប្រាថ្នាចង់បានសេចក្តីសុខ ។
យើងខេមរជាតិ នាំគ្នាខ្មីឃ្មាត កាន់ធម៌នឹងបានផុតទុក្ខ
រួបរួមសាមគ្គី ពីនេះទៅមុខ យើងនឹងបានសុខក្សេមក្សាន្តត្រាណ។
ព្រមព្រៀងប្រព្រឹត្ត កាន់ធម៌សុចរិត ឆ្ពោះទៅកាន់ស្ថាននិព្វាន
ជាទីផុតទុក្ខ បានសុខក្សេមក្សាន្ត ជាតិយើងនឹងបានសោយសុខា ។

បទគន់មើលទៅមេឃ

១. គន់មើល មើលទៅមេឃ មេឃមីស្រទុំ ពពកបាំងភ្នំ បាំងភ្នំខ្យល់បក់ផាត់ផាយ
ដងភ្នំពពាល វាលវែងអន្លាយ ពពកខ្ចាត់ខ្ចាយ បៃប្រែក្លាយរសោត់តាមខ្យល់ ។

២. ខ្យល់អើយ អើយខ្យល់ បក់ម្តេចមិនល្ហើយ កម្លាំងក៏មិនស្បើយ កាន់តែល្វើយ
ភ្លេចភ្លាំងស្មារតី គន់មើលទៅមេឃ មេឃខ្ពស់សែនធ្ងាយពេកក្រៃ
ចិត្តខ្ញុំអាល័យ អាល័យស្រុកពន់ពេកប្រមាណ ។

៣. ក្រុមទាហានខំដើរដេកតាមដងព្រៃភ្នំ អាវុធគួចធំធ្ងុំទប់ទល់ តនឹងសត្រូវ ដៃ
កាន់កាំភ្លើង នាំគ្នារត់ចូលចំដៅ ព័ន្ធខ្មាំងឥឡូវ ត្រូវតែយើងដណ្តើមយកជ័យ ។

៤. ជ័យនេះបានមកពីទឹកចិត្តហានក្លា បីដូចសត្វខ្លាៗ ស្វែងរកចំណី បើបានជួប
ហើយស្លាប់រស់យើងកុំគិតអី ធ្វើឱ្យល្បាញល្បីនៃរាជាណាចក្រកម្ពុជា ។

បទដែនដីខ្មែរ

ដែនដីខ្មែរប្រៃថាសុវណ្ណភូមិ ខ្មែរគ្រប់ភូមិរមណីយដ្ឋាន

រៀងដរាបតមកតាំងពីបុរាណ ខ្មែរយើងបានសមាគមសាមគ្គី។

ថ្ងៃមួយមានសត្រូវប្រទូសរ៉ាយ ខ្មែរគ្រប់កាយស្ម័គ្រចិត្តប្តូរជីវី

សឹកសង្គ្រាមឈាមស្រក់លើប្រឹថពី ព្រះភូមីឫទ្ធិវង្សគង្គា។

កម្ពុជាឯករាជ្យបានឃ្លាតពីទុក្ខ ខ្មែរបានសុខទាំងអស់គ្រប់អាត្មា

សូមទេវតាឲ្យពរសព្វសាធុការ ព្រះមហាក្សត្រយើងគ្រប់គ្រងផែនដី។

បទពហ្មវិថីតារខ្មែរ

១. ខ្មែរអើយ ចូរចាំជាក់ថា តាមសាវតារ ជាតិខេមរាធ្លាប់តែថ្កើង ទឹកដីខ្មែរធំ
ទូលំទូលាយ សព្វសាយរុងរឿង គេងង តែងលើកតម្កើង តម្កល់ជាតិ
យើង ចាត់ទុកឡើងជាជាតិច្បង។

២. អារ្យធម៌ ខ្ពង់ខ្ពស់ឆើតឆាយ បានចេញផ្សព្វផ្សាយ គ្រប់ទិសទាំងឡាយ
ចុងបូព៌ា សាសនាសិល្បៈ ចម្លាក់វិចិត្រ គំនិតសិក្សា តន្ត្រី ទស្សនវិជ្ជា ព្រះ
ពុទ្ធសាសនា ជាគោលការណ៍ខ្មែរផ្សាយទៅ។

៣. ខ្មែរអើយ ចូរស្តាប់សាវតារ ដែលបានចរចា បញ្ជាក់ប្រាប់ថា
ពូជខ្មែរថ្កើង តាំងចិត្តឲ្យមាំ ខិតខំប្រឹងវេញ បញ្ចេញតម្កើង
តម្លៃ នៃជាតិខ្មែរយើង ឲ្យបានរុងរឿង ជាថ្មីឡើងតាមសាវតារ។

បទឆ្កួតបីប្រការ

១.	លោកថាឆ្កួតបី	ឆ្កួតមួយនឹងស្រី	ឆ្កួតមួយនឹងស្រា
	ឆ្កួតមួយនឹងល្បែង	អំពើពាលា	ឆ្កួតនេះហៅមហា
		ឆ្កួតក្រៃកន្លង។	
២.	ឆ្កួតស្រីឆ្កួតស្រា	ឆ្កួតល្បែងពាលា	អំពើសឹងឆ្គង
	លោកពុំឱ្យសេព	ឱ្យវៀរជាម្ដង	វាតែងឱ្យហ្មង
		ភ្លេចភ្លាំងស្មារតី។	
៣.	ឱ្យភ្លេចក្ដីគាប់	ភ្លេចទាំងខ្លួនស្លាប់	ភ្លេចសាស្ត្រសួស្ដី
	ភ្លេចសីលភ្លេចទាន	ភ្លេចញាណវុឌ្ឍី	ភ្លេចច្បាប់ប្រក្រតី
		ឆ្កួតបីប្រការ។	